# សេចក្តីថ្លែងការណ៍រួម

*រាជធានីភ្នំពេញ ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២៣*—ការប្រារព្ធខួបទី៣០នៃទិវាសេរីភាពសារព័ត៌មាននៅឆ្នាំ២០២៣នេះត្រូវបានធ្វើឡើងរួមគ្នា នៅព្រឹកថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៣ ក្នុងរាជធានីភ្នំពេញ ដោយក្រុមអង្គការសមាគមសារព័ត៌មាន និងអង្គការសមាគមមិនមែនរដ្ឋាភិបាលជាង១០ ក្រោមកិច្ចសហការជាមួយបណ្តាដៃគូអភិវឌ្ឍន៍។ ព្រឹត្តិការណ៍នេះមានអ្នកចូលរួមប្រមាណ២០០នាក់ រួមមាន អ្នកសារព័ត៌មាន តំណាងអង្គការសង្គមស៊ីវិល យុវជន ព្រមទាំងភាគី ពាក់ព័ន្ធផ្សេងទៀត។

ទិវាដ៏សំខាន់នេះ ប្រព្រឹត្តទៅក្រោមប្រធានបទ "**ការកំណត់អនាគតនៃសិទ្ធិ៖ សេរីភាពនៃការបញ្ចេញមតិជាកម្លាំងចលករនៃសិទ្ធិមនុស្សដទៃទៀត**" ។ ក្រុមអង្គការ សមាគមសារព័ត៌មាន និងអង្គការសមាគមមិនមែនរដ្ឋា-ភិបាលដែលធ្វើការងារពាក់ព័ន្ធនឹងការលើកកម្ពស់សិទ្ធិទទួលព័ត៌មាន សេរីភាពសារព័ត៌មាន និងសេរីភាពបញ្ចេញមតិក្នុងប្រទេសកម្ពុជា ដូចមានរាយនាមខាងក្រោម ទទូចស្នើសុំដល់រាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធទាំងអស់ ឱ្យបន្តយកចិត្តទុកដាក់ឱ្យបានច្រើនជាងនេះ ដើម្បីពិនិត្យតាមដាន និងដោះស្រាយនូវសំណើដូចខាងក្រោម៖

1. ធានាឱ្យបាននូវបរិយាកាសប្រកបដោយសេរីភាព សន្តិសុខ និងសុវត្ថិភាពពេញលេញសម្រាប់អ្នកសារ-ព័ត៌មាន និងស្ថាប័នព័ត៌មាន ក្នុងការបំពេញការងារវិជ្ជាជីវៈដោយមិនមានការរឹតត្បិត និងភ័យខ្លាច ជាពិសេសនៅមុន អំឡុងពេល និងក្រោយពេលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅខែកក្កដា ខាងមុខនេះ។
2. ស្នើដៃគូអភិវឌ្ឍន៍បង្កើនការផ្តល់ការគាំទ្រដល់សារព័ត៌មានឯករាជ្យ ព្រមទាំងស្ថាប័នសង្គមស៊ីវិលដែលផ្តល់សេវាការពារ និងជួយសង្គ្រោះបន្ទាន់ដល់អ្នកសារព័ត៌មានដែលស្ថិតក្នុងហានិភ័យ ដោយសារការបំពេញការងារវិជ្ជាជីវៈរបស់ពួកគេ។
3. បញ្ឈប់រាល់ការធ្វើទុក្ខបុកម្នេញគ្រប់ប្រភេទទៅលើស្ថាប័នសារព័ត៌មាន និងអ្នកសារព័ត៌មានដែលហ៊ានរាយការណ៍បញ្ហាអសកម្មផ្សេងៗក្នុងសង្គម ហើយដោះលែងអ្នកសារព័ត៌មានទាំងឡាយណាដែលកំពុងជាប់ពន្ធនាគារដោយសារការបំពេញវិជ្ជាជីវៈសារព័ត៌មាន ជាពិសេសសូមបញ្ឈប់ការប្រើប្រាស់ច្បាប់ស្តីពីក្រម-ព្រហ្មទណ្ឌដាក់ទោសទណ្ឌអ្នកសារព័ត៌មាន។
4. ស្នើឱ្យរាជរដ្ឋាភិបាល និងសភាជាតិ អនុម័តឱ្យបានឆាប់នូវច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ដែលស្របតាមបទដ្ឋានអន្តរជាតិ និងមានប្រសិទ្ធភាពក្នុងការអនុវត្ត។
5. ស្នើឱ្យរាជរដ្ឋាភិបាលបើកឱ្យមានការប្រឹក្សាយោបល់ទូលំទូលាយ និងទទួលយកនូវធាតុចូលពីដៃគូពាក់ព័ន្ធ ក្នុងដំណើរការនៃការធ្វើវិសោធនកម្មច្បាប់ស្តីពីរបបសារព័ត៌មាន និងការធ្វើសេចក្តីព្រាងច្បាប់ថ្មីៗមួយចំនួនដូចជា សេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យា សេចក្តីព្រាងច្បាប់ស្តីពីសន្តិ-សុខសាយប័រ និងវិធានគតិយុត្តផ្សេងទៀតដែលអាចនឹងប៉ះពាល់ដល់សេរីភាពសារព័ត៌មាន និងសេរី-ភាពបញ្ចេញមតិ។

6. ស្នើឱ្យរាជរដ្ឋាភិបាលបង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការលុបបំបាត់រាល់ទម្រង់នៃការបៀតបៀនលើអ្នក-សារព័ត៌មានស្ត្រី ដើម្បីបង្ហាញពីការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការជួយជំរុញឱ្យមានការចូលរួមកាន់តែច្រើនឡើងនៃចំនួនស្ត្រីនៅក្នុងវិស័យសារព័ត៌មាន។

**សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖**

លោក ណុប វី នាយកប្រតិបត្តិសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា)

012 519 261; ed@camboja.net

អ្នកស្រី ធន សុគន្ធា នាយិកាស្តីទីនៃមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ

093 831 990, csokunthea@ccimcambodia.org

**អង្គការសមាគមមិនមែនរដ្ឋាភិបាល ដែលចូលរួមគាំទ្រសេចក្តីថ្លែងការណ៍នេះរួមមាន ៖**

1. សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (CamboJA)
2. មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)
3. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
4. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)
5. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL)
6. បណ្តាញយុវជនកម្ពុជា (CYN)
7. អង្គការកម្មវិធីអភិវឌ្ឍន៏ធនធានយុវជន (YRDP)
8. អង្គការអភិឌ្ឍន៍សំលេងសហគមន៍ (BCV)
9. មណ្ឌលព័ត៌មាន ស្ត្រីកម្ពុជា (WMC)
10. សមាគមការពារសិទ្ធិមនុស្ស និងអភិឌ្ឍន៍នៅកម្ពុជា (ADHOC)
11. អង្គការថែរក្សាភាសាជនជាតិដើមភាគតិច (CIPL)
12. អង្គការតម្លាភាពកម្ពុជា (TIC)
13. អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD)